ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

# ស្ថានអគ្គកុងស៊ុលប្រចាំខេត្តសាកែវ ស្វែងរកការលើកលែងទោសដល់ពលរដ្ឋខ្មែរ២៤នាក់

------------

ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ ប្រទេសថៃ បានធ្វើអន្តរាគមន៍ជួយពលរដ្ឋខ្មែរចំនួន **២២នាក់** ដែលត្រូវបានអាជ្ញាធរថៃឃុំខ្លួនពីបទក្លែងបន្លំនិងប្រើប្រាស់លិខិតឆ្លងដែនក្លែងបន្លំ និង**០២នាក់**ទៀត ពីបទចូលរួមពាក់ព័ន្ធ។ នៅថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០១៧ ស្ថានអគ្គកុងស៊ុល បានបញ្ជូនមន្ត្រីទៅជួបផ្ទាល់ជាមួយពលរដ្ឋខ្មែរទាំង២៤នាក់នៅពន្ធនាគារខេត្តសាកែវ ហើយទទួលបានព័ត៌មានថា ពលរដ្ឋខ្មែរទាំងនោះ បានចំណាយប្រាក់ឲ្យមេខ្យល់ នៅក្រុងប៉ោយប៉ែតចំនួន**២៥០០**បាតក្នុងម្នាក់ សំរាប់លិខិតឆ្លងដែន និង**១០០០**បាតក្នុងម្នាក់ សម្រាប់ធ្វើដំណើរតាមរថយន្តទៅកាន់គោលដៅធ្វើការរៀងៗខ្លួន។

តាមការពិនិត្យរបស់ស្ថានអគ្គកុងស៊ុល លិខិតឆ្លងដែនទាំង២២ ពិតជាក្លែងក្លាយមែន។

បច្ចុប្បន្ន ពលរដ្ឋខ្មែរទាំង២៤នាក់ ត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ននៅពន្ធនាគារខេត្តសាកែវ ដោយពុំមានការធ្វើបាប ឬការធ្វើទុក្ខបុកម្នេញអ្វីឡើយ ហើយទទួលបានការផ្តល់របបអាហារ៣ពេលក្នុងមួយថ្ងៃ។

ស្ថានអគ្គកុងស៊ុល កំពុងស្វែងរកមេធាវីស្ម័គ្រចិត្តជួយការពារក្តីឲ្យពលរដ្ឋខ្មែរទាំង២៤នាក់ ក្នុងពេលកាត់ក្តីនាពេលខាងមុខ ហើយនឹងស្នើសុំការយោគយល់លើកលែងទោសដល់ពួកគាត់ផងដែរ។

(បញ្ជីឈ្មោះពលរដ្ឋខ្មែរទាំង២៤នាក់ មានជូនភ្ជាប់)

ភ្នំពេញ, ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៧

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ